# ព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍
# WEEKLY BULLETIN

CRF 2020/032 (ថ្ងៃទី២១ កញ្ញា ដល់ទី០៤ ខែតុលា ឆ្នាំ២០២០)

CRF 2020/032 (21 September to 04 October 2020)

## សង្ខេបព័ត៌មានសំខាន់ៗអំពីវិស័យស្រូវអង្ករប្រចាំសប្តាហ៍ (Rice News Briefing)

## ក្នុងប្រទេស (In Cambodia)



### សហគមន៍ចំនួន៥៩ ចូលរួមក្នុងកិច្ចសន្យាកសិកម្ម
### Fifty-nine communities enter agri-contracting

*Phnom Penh Post: Sept 29, 2020*

Fifty-nine communities on Tuesday signed agricultural production contracts for agro-industrial crops and organic rice with four companies in a bid to boost production and secure export markets. Witnessing the signing, Minister of Agriculture Forestry and Fisheries Veng Sakhon lauded the move as a model for such contracts, highlighting the good cooperation between all relevant parties to ensure sustainable agricultural supply, product quality and price guarantee, while establishing solidarity and trust.

The communities are based in Takeo, Kampong Speu, Kampot, Kampong Chhnang, Mondulkiri, Preah Vihear, Banteay Meanchey and Siem Reap provinces. (Read more)

### កិច្ចព្រមព្រៀងកសិកម្មតាមកិច្ចសន្យាជាច្រើនទៀតត្រូវបានចុះហត្ថលេខា
### More contract farming deals signed

*Khmer Times: Sept 30, 2020*

Some 50 agricultural cooperatives have signed contract farming with four agricultural firms and rice millers, supplying paddy organic rice and organic cassava. The signing ceremony was held Tuesday led by Veng Sakhon, Minister of Agriculture, Forestry, and Fisheries with the participation of representatives of agricultural cooperatives, rice millers, and Cambodian Rice Federation, Cambodia-Australia Agriculture Value Chain Programme (CAVAC). Contract farming is an agreement between farmers and processing and/or marketing firms for the production and supply of agricultural products under forward agreement, (Read more)





### រដ្ឋមន្ត្រីមានប្រសាសន៍ថា ថ្ងៃឈប់សម្រាកច្រើនថ្ងៃបានធ្វើឱ្យការនាំចេញធ្លាក់ចុះ
### Minister says holidays slash exports

*Khmer Times: Oct 02, 2020*

The Minister of Agriculture has blamed a decline in exports of agricultural produce within the last two months on the number of public holidays in the country.

Speaking to about 100 farmers and exporters during the contract-farming signing ceremony in Phnom Penh this week, Veng Sakhon, from the Ministry of Agriculture, Forestry and Fisheries (MAFF) said rice export for the last two months, August and September, fell nearly 30 percent each month. He said it is different from other countries where every public holiday does not stop exports and imports services. He wants the ministry to remain open during public holidays. (Read more)

### ការនាំអង្ករចេញរបស់កម្ពុជាកើនឡើង ២២%ក្នុងរយៈពេល ៩ខែដំបូងដល់ជិត ៥០ម៉ឺនតោន
### Cambodia's rice export increases by 22% in first 9 months to nearly 500,000 tonnes

*Khmer Times: Sept 30, 2020*

Cambodia exported 488,775 tonnes of milled rice in the first nine months of this year, up 22.6 percent compared to the same period last year. Figures from the Ministry of Agriculture, Forestry, and Fisheries showed that Cambodian milled rice was shipped to 60 countries around the world.

The ministry also mentioned that as of September this year, paddy rice cultivation was carried out on 2.7 million hectares nationwide, equivalent to 104 percent of the yearly plan. Chea Vannak – AKP





### ការនាំចេញអង្កររបស់កម្ពុជាឈានដល់ ៤៩ម៉ឺនតោន
### Rice exports of Cambodia hit 490,000 tons

*MENA FN: Oct 03, 2020*

The Cambodia Rice Federation said on Saturday that Cambodia has exported a total of 488,785 tons of milled rice in the starting nine months of 2020, rising 23 percent compared to the same period a year ago.

Cambodia made over USD328 million in gross revenue from the commodity's export in the cited period of this year, according to a statement. The statement said that "within nine months of export this year, China is the lead market, absorbing 35 percent of overall market destinations, which the amount is 171,896 tons, and the European Union is the second lead, absorbing 33 percent, generating in the amount of 161,614 tons". (Read more)



## ការនាំចេញអង្ករ៩ខែដំបូង ទទួលបានចំណូល៣០០លានដុល្លារ
## Rice exports top $300M in first nine months of year

*Phnom Penh Post: Oct 04, 2020*

Cambodia rice exports in the first nine months of the year topped $300 million, an increase of more than 10 per cent, according to a report by the Cambodia Rice Federation (CRF).The data shows that from January to September, Cambodia brought in more than $328 million from rice exports, up from $297 million in the same period last year.

Cambodia exported a total of 488,785 tonnes of rice, an increase of 22.62 per cent year-on-year, which was 398,586 tonnes, said the data. China remains the largest export market and buys 35 per cent or 171,896 tonnes of rice. (Read more)

# អន្តរជាតិ ( International )

ឥណ្ឌា ( India )

### ទិន្នផលគ្រាប់ធញ្ញជាតិនៅរដូវក្តៅរបស់ឥណ្ឌាត្រូវបានគេមើលឃើញថាមានចំនួន ១៤៤.៥២ លានតោនក្នុងឆ្នាំ ២០២០/២១
### India's summer-sown grains output seen at 144.52 million tonnes in 2020/21

*Reuters: Sept 22, 2020*



NEW DELHI (Reuters) - Indian farmers are expected to harvest a record 144.52 million tonnes of grains from summer-sown crops in the crop year to June 2021, the government said on Tuesday, against 143.38 million tonnes gathered in the previous year. In 2020/21, the output of summer-sown rice is estimated at a record 102.36 million tonnes, up from 101.98 million tonnes in 2019/20, the Ministry of Agriculture and Farmers' Welfare said in a statement. (Read more)

វៀតណាម ( Vietnam )

### ការនាំចេញអង្កររបស់វៀតណាមទៅសហភាពអឺរ៉ុបត្រូវបានលក់ក្នុងតម្លៃល្អ
### Vietnam's rice exports to EU sell at good prices

*Vietnam Net: Sept 25, 2020*



With the new EVFTA, more and more Vietnamese rice is being shipped to the EU. Scented rice in particular is being sold at high prices.

Rice, coffee, shrimp and fruits are exported to the EU under the EVFTA, which took effect on August 1. One more consignment of scented rice departed from An Giang province to the EU on September 22. (Read more)

អាស៊ី ( Asia )

### អត្រាអង្ករនៅអាស៊ី - វៀតណាមបានធ្លាក់ចុះនៅពេលប្រមូលផលបានចាប់ផ្តើម ហើយហ្វីលីពីនបញ្ឈប់ការទិញ
### Asia rice-Vietman rates drop as harvest begins, Philippines halts buying

*VN Explorer: Sept 25, 2020*



Rice export prices fell in top hubs this week, with rates in Vietnam extending a slide as the Philippines halted purchases and the onset of a new harvest added pressure.

Vietnam's rates for 5% broken rice eased to $470-$475 a tonne on Thursday, from a range of $485-$490 a tonne a week earlier. "The autumn-winter harvest has started at some parts of the Mekong Delta, including Bac Lieu and Dong Thap provinces," (Read more)

មីយ៉ាន់ម៉ា ( Myanmar )

### ការនាំចេញអង្កររបស់មីយ៉ាន់ម៉ា ឈានដល់លើសគោលដៅរំពឹងទុក ក្នុងឆ្នាំ២០១៩-២០២០
### Myanmar surpasses rice export target in FY 2019-2020

*Xinhua Net: Sept 29, 2020*

YANGON, Sept. 29 (Xinhua) -- Myanmar has managed to achieve its rice export target of 2.5 million tons in over 11 months of the present fiscal year (FY) 2019-2020, an official from the Myanmar Rice Federation told Xinhua on Tuesday. As of Sept. 11 in the present FY, the country exported over 2.53 million tons of rice and broken rice.

"Rice export target was set to 2.5 million tons in early months of FY 2019-2020 and was later reduced to 2.4 million tons due to the outbreak of the COVID-19 pandemic. But we, somehow, managed to surpass the target, thanks to the efforts exerted by all stakeholders," Myint Lwin, chief executive officer of the federation said. (Read more)

ថៃ ( Thailand )

### សហគមន៍អ៊ឺរ៉ុបនឹងអនុញ្ញាតឱ្យនាំចូលអង្ករថៃជាង ២៤០០០ តោនដោយមិនបង់ពន្ធក្នុងខែតុលា
### EU to allow duty-free import of over 24,000 tonnes of Thai rice in October

*The Nation: Sept 30, 2020*



The Commerce Ministry is getting ready to issue a certificate for exporting 24,883 tonnes of rice to the European Union under zero tariff in October. Kirati Ratchano, deputy director-general of the Department of Foreign Trade, revealed on Tuesday that on September 22, the European Commission issued a notification on the remaining quota for white rice (white rice, Thai jasmine rice, Thai fragrant rice and parboiled rice) (Read more)

ថៃ ( Thailand )

### តើប្រព័ន្ធបច្ចេកវិទ្យាវិភាគ DNA អាចជួយគ្រប់គ្រងគុណភាពប្រណីត របស់អង្ករហូមម៉ាលីរបស់ថៃយ៉ាងដូចម្តេច?
### How DNA technology helps control the premium quality of Thai Hom Mali Rice

*Open Access Government: Oct 01, 2020*



Professor Dr Apichart Vanavichit, at the Rice Science Center, explains how DNA technology can create a high-quality Thai Jasmine Rice.

**Products of the poor**

Hom Mali rice has been widely grown in one of the poorest land on the largest lowland rain-fed paddy field in the Northeast of Thailand. With its low soil fertility (Read more)

អាស៊ី ( Asia )

### អត្រាអង្ករអាស៊ីធ្លាក់ចុះនៅចំណុចកណ្តាល ខណៈពាណិជ្ជករចង្អុលបង្ហាញពីកំរិតទឹកទន្លេមេគង្គទាប
### Asia Rice-Rates dip in top hubs; traders flag low Mekong water levels

*Reuters: Oct 01, 2020*

Rice export prices eased this week in most hubs on lackluster demand with fresh supplies expected to be a further drag, but Vietnamese traders were concerned about low water levels in the Mekong.

Top exporter India's 5% broken parboiled variety RI-INBKN5-P1 slipped to $376-$382 per tonne from last week's $379-$385.

"Local prices are softening due to the expected rise in production. Exports prices are not falling in the same proportion because of rising rupee," said an exporter based at Kakinada in the southern state of Andhra Pradesh. (Read more)

ថៃ ( Thailand )

### រូបិយប័ណ្ណថៃឡើងខ្ពស់ តែផលិតកម្មស្រូវទាបនាំឱ្យការនាំចេញរបស់ថៃធ្លាក់ចុះ
### Strong Thai currency, low rice production weighs down Thai rice exports

*Xinhua Net: Oct 05, 2020*

The Thai Rice Exporters Association said said on Monday that Thailand's rice export this year is expected to drop from 7.5 million tons estimated at 130 billion baht (4.138 billion U.S. dollars) last year to 5 million tons estimated at 115 billion baht (3.66 billion U.S. dollars).

The association's president Chookiat Ophaswongse, attributed the drop to the strengthening of the Thai baht and low rice production.

The price of Thai white rice is currently around 490 U.S. dollars per ton, compared to Vietnamese white rice at 460 U.S. dollars per ton, Indian at 370 U.S. dollars per ton and Myanmar at 420 U.S. dollars per ton, Chookiat said. (Read more)

# ពិធីចុះកិច្ចសន្យាផលិតកម្មកសិកម្ម លើដំណាំកសិ-ឧស្សាហកម្ម និងស្រូវសរីរាង្គ រវាងក្រុមហ៊ុន និងសហគមន៍កសិកម្ម នៅប្រទេសកម្ពុជា




កិច្ចសន្យាកសិកម្ម គឺជាយន្តការមួយដែលសមស្រប និងជួយជំរុញក្នុងការដាំដុះ ការផ្គត់ផ្គង់ និង ប្រភេទពូជដែលឆ្លើយតបទៅនឹងតម្រូវការ លក្ខខណ្ឌទីផ្សារជាពិសេស ប្រភេទស្រូវ និងដំណាំកសិផលសរីរាង្គ ហើយជាយន្តការមួយជួយធានា និងបង្កើនទំនុកចិត្តលើការដាំដុះរបស់ប្រជាកសិករផងដែរ។

ដោយមើលឃើញនូវសារៈសំខាន់នៃយន្តការនេះ សហព័ន្ធស្រូវអង្ករកម្ពុជាសហការណ៍ជាមួយនាយកដ្ឋានកសិឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការរៀបចំនូវព្រឹត្តិការណ៍ "ពិធីចុះកិច្ចសន្យា ផលិតកម្មកសិកម្ម លើដំណាំកសិ-ឧស្សាហកម្ម និងស្រូវសរីរាង្គ រវាងក្រុមហ៊ុន និងសហគមន៍កសិកម្ម នៅប្រទេសកម្ពុជា" ដែលរៀបចំឡើងនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ ក្រោមអធិបតីភាព ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយនឹងវត្តមានរបស់ភាគីពាក់ព័ន្ធជាង១០០នាក់ ក្នុងនោះ មានសហគមន៍កសិកម្មចំនួន៥៩ មកពី៨ខេត្ត ទូទាំងប្រទេសកម្ពុជា។

សហគមន៍កសិកម្មទាំង៥៩ មានទីតាំងនៅក្នុងខេត្តតាកែវ កំពង់ស្ពឺ កំពត កំពង់ឆ្នាំង មណ្ឌលគិរី ព្រះវិហារ ដែលមានសមាជិកសរុបចំនួន៤២៤៣ គ្រួសារ បានទទួលនូវទីផ្សារផលិតនិងផ្គត់ផ្គង់ដំណាំកសិ-ឧស្សាហកម្ម និងស្រូវសរីរាង្គ ពីការចុះកិច្ចសន្យាផលិតកម្មកសិកម្មតាមកិច្ចសន្យានាថ្ងៃនេះ។ ជាមួយគ្នានេះផងដែរ សម្រាប់កម្មវិធីថ្ងៃនេះគឺ មានសហគមន៍ចំនួន ៥៩ មកពីខេត្តចំនួន៨ ដែលចុះកិច្ចសន្យាផលិត ផ្គត់ផ្គង់ ស្រូវសរីរាង្គចំនួនជិត ៣ម៉ឺនតោន ដំឡូងមីសរីរាង្គចំនួន ២ម៉ឺន៦ពាន់តោន ស្ករត្នោតកំពង់ស្ពឺ ១០០តោន និង ម្រេច ចំនួន ៥០តោនផងដែរ។



ពិធីចុះកិច្ចសន្យាផលិតកម្មកសិកម្មតាមកិច្ចសន្យានេះ ត្រូវបានសហការរៀបចំឡើង ដោយសហព័ន្ធស្រូវអង្ករកម្ពុជា និងនាយកដ្ឋានកសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជាមួយគ្នានេះផងដែរ កម្មវិធីនេះទទួលបានការចូលរួមគាំទ្រផ្នែកហិរញ្ញវត្ថុ ពីរដ្ឋាភិបាលប្រទេសអូស្ត្រាលីតាមរយៈកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី (CAVAC) ក្រុមហ៊ុន អេមរុ រ៉ាយកម្ពុជា ខេមបូឌា ឯ.ក(Amru Rice) ក្រុមហ៊ុនសាជីវកម្មកសិកម្មកម្ពុជា ម.ក (CACC) ក្រុមហ៊ុន Signatures of Asia ឯ.ក ក្រុមហ៊ុន បាយ៉ន់ហេរីធេច (Bayon Heritage) ឯ.ក សហព័ន្ធបណ្តាញកសិកម្ម និងធម្មជាតិ (FNN) សហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ អង្គការអភិវឌ្ឍ និងភាពជាដៃគូក្នុងសកម្មភាព (DAP) ព្រះវិហាដាណឺម៉ាក់ (DCA)។ មិនតែប៉ុណ្ណោះ ពិធីនេះ ក៏ទទួលបាននូវការគាំទ្រយ៉ាងពេញទំហឹងពី ក្រសួងកសិកម្ម ក្រសួងពាណិជ្ជកម្ម ធនាគារអភិវឌ្ឍជនបទ និងកសិកម្ម (ARDB)។

នៅក្នុងកម្មវិធីនេះដែរ ឯកឧត្តម រដ្ឋមន្ត្រី វេង សាខុន ក៏បានធ្វើការវាយតម្លៃខ្ពស់ ចំពោះរបាយការណ៍ស្វាគមន៍របស់នាយកដ្ឋានកសិ-ឧស្សាហកម្ម ដែលមាន លោក គង់ ភាជ ជាប្រធាននាយកដ្ឋាន និងជាដៃគូសហការជាមួយសហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការរៀបចំព្រឹត្តិការណ៍នាថ្ងៃនេះឡើង។ ឯកឧត្តមបានថ្លែងថា ព្រឹត្តិការណ៍នាថ្ងៃនេះ បានបង្ហាញឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែង សហការគ្នាបានយ៉ាងល្អ ពីគ្រប់ភាគីពាក់ព័ន្ធ ឈានមកសម្រេចបាននូវកិច្ចសន្យាមួយដែលអាចចាត់ទុកថាជាបន្ទាត់ ជាខ្សែ ឬជានិតិវិធីសម្រាប់ឲ្យភាគីអ្នកផលិត និងអ្នកបញ្ជាទិញដើរព្រមគ្នាឆ្ពោះទៅទិសដៅមួយយ៉ាងជាក់លាក់ ពិតប្រាកដ យុត្តិធម៌ តម្លាភាព សច្ចភាព និងជំនឿទុកចិត្តគ្នា ដោយឈរលើគោលការណ៍សំខាន់៣ គឺ៖ ធានាបាននូវបរិមាណផ្គត់ផ្គង់ប្រកបដោយនិរន្តរភាព គុណភាពផលិតផល ធានាបាននូវតម្លៃ និងធានាបាននូវសាមគ្គីភាព កិច្ចសហការ និងជំនឿទុកចិត្ត។

ឯកឧត្តមមានប្រសាសន៍ថា ៖ *"ពិតណាស់លទ្ធផលនាពេលនេះបានឆ្លុះបញ្ចាំងឲ្យឃើញថា ក្រសួងកំពុងតែបន្តជំរុញ និងលើកទឹកចិត្តឲ្យគ្រប់អនុវិស័យទាំងអស់អនុវត្តតាមអភិក្រម "រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍" ដើម្បីពង្រីកវិសាលភាពឲ្យបានកាន់តែទូលំទូលាយទៅដល់សហគមន៍ផ្សេងៗទៀត ក្នុងទិសដៅចូលរួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤ និងសាកលភាវូបនីយកម្ម"*។ ឯកឧត្តម បានឱ្យដឹងទៀតថា មកទល់ពេលនេះមានសហគមន៍កសិកម្មជាង៧៥០ហើយ ដែលបានចុះកិច្ចសន្យាផ្គត់ផ្គង់កសិផលទៅឱ្យក្រុមហ៊ុនធ្វើការនាំចេញ និងរំពឹងថា ចំនួនកិច្ចសន្យានេះ នឹងកើនឡើងដល់១ពាន់សហគមន៍នៅត្រឹមដំណាច់ឆ្នាំ២០២០នេះ។





ឧកញ៉ា ចាន់ សុឃាំង អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ក៏បានលើកឡើងអំពីយន្តការណ៍4P ( Public Private Producer Partnership ) និងសមិទ្ធផលដែលសំរេចបានជាពិសេស ពិពិធកម្មទីផ្សារ ទៅសហគមន៍អឺរ៉ុប កើនជាង ៣០ភាគរយ ទីផ្សារអូស្ត្រាលីកើនជិត ១០០០% ហើយទីផ្សារហុងកុង កើនជាង ២០០% ផងដែរ ។ល។ សម្រាប់ព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ថ្ងៃនេះគឺពិតជាបានចូលរួមចំណែកយ៉ាងធំធេងក្នុងការជំរុញ និងការធ្វើពាណិជ្ជកម្មស្រូវ-អង្ករនៅកម្ពុជា ជាពិសេសស្រូវសរីរាង្គ។ លោកឧកញ៉ាបានបញ្ជាក់ថា រយៈកាលកន្លងមកនេះ គឺ មានសមាជិកសហព័ន្ធមួយចំនួនបាន និងកំពុងអនុវត្តដោយផ្ទាល់ជាមួយសហគមន៍កសិករនៅតាមមូលដ្ឋានដោយផ្ទាល់។ លោកឧកញ៉ាមានប្រសាសន៍បន្ថែមថា ៖ *"សកម្មភាពការងាររបស់ សហព័ន្ធបានចូលរួមចំណែកក្នុងគោលនយោបាយជំរុញការនាំចេញអង្ករកម្ពុជា ដែលជាវេទិកាប្រមូលផ្តុំភាគីពាក់ព័ន្ធនៅក្នុងវិស័យ កសិកម្ម ជាពិសេសស្រូវអង្ករ ហើយនឹងក្លាយទៅជាកម្មវិធីគំរូសម្រាប់បណ្តារោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនអ្នកនាំចេញ និងសហគមន៍កសិករផ្សេងៗទៀត នៅតាមបណ្តាខេត្តផ្សេងៗទៀតក្នុងការអនុវត្តនូវកិច្ចសន្យាផលិតកម្មកសិកម្ម ការអនុវត្តន៍កិច្ចសន្យាគឺ ជាការផ្តល់ទំនុកចិត្តទៅវិញទៅមករវាងអ្នកផលិត និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ ហើយដើម្បីអោយកាន់តែជោគជ័យថែមទៀតនោះគឺ ការចូលរួមនៅក្នុងខ្សែច្រវាក់តម្លៃ និងការផ្គត់ផ្គង់ពីគ្រប់ភាគីទាំងអស់ រួមទាំង វិស័យសាធារណៈ និង វិស័យឯកជនផ្នែកទៀតដូចជាធនាគារជាដើម។"*



ពិតណាស់ ពិធីចុះកិច្ចសន្យាកសិកម្មនាថ្ងៃនេះ ប្រព្រឹត្តទៅដោយជោគជ័យ និងប្រកបដោយផ្លែផ្កា ពិតជាមិនអាចខ្វះបាននោះទេ នូវការចូលរួមគាំទ្រផ្នែកហិរញ្ញវត្ថុ ពីដៃគូអភិវឌ្ឍ។ លោក Gary Ellem ប្រធានក្រុមការងារកម្មវិធីកាវ៉ាក់ បានថ្លែងថា កម្មវិធីកាវ៉ាក់ គឺជាកម្មវិធីដែលបានជំនួយពីរាជរដ្ឋាភិបាលអូស្ត្រាលី ដែលគាំទ្រលើការលើកកម្ពស់ដល់ការប្រកួតប្រជែង នៃវិស័យកសិកម្មកម្ពុជា តាមរយៈយុទ្ធសាស្ត្រផ្សេងៗ ការធ្វើការរួមសហការជាមួយរាជរដ្ឋាភិបាល វិស័យឯកជន និងគ្រឹះស្ថានស្រាវជ្រាវនានា។ ចាប់តាំងពីកម្មវិធីកាវ៉ាក់ បានធ្វើការសហការជាមួយក្រុមហ៊ុន AMRU Rice ចាប់ផ្តើមនៅឆ្នាំ២០១៨ លើផលិតកម្មកិច្ចសន្យាកសិកម្ម ក្នុងនោះ បរិមាណដែលបានចុះកិច្ចសន្យាកើនឡើងពី ២០០០ តោន នៅឆ្នាំ ២០១៨ ដល់ ៣០០០ តោន នៅឆ្នាំ ២០១៩ ហើយ នៅឆ្នាំ ២០២០ បរិមាណដែលបានចុះកិច្ចសន្យានឹងកើនឡើងដល់ ៥០០០ តោន។ នេះជាការរីកចំរើនដែលគួរឲ្យកត់សម្គាល់។ លោកមានប្រសាសន៍ថា ៖ *"នៅក្នុងកសិកម្មកិច្ចសន្យាមានបញ្ហាប្រឈមជាច្រើន ប៉ុន្តែកម្មវិធីកាវ៉ាក់គឺរីករាយនឹងចូលរួមក្នុងការអភិវឌ្ឍគំរូមួយដែលយើងជឿជាក់ថាកសិកម្មកិច្ចសន្យាអាចនឹងពង្រីកទៅខេត្តផ្សេងទៀត ដោយមានស្ថាប័នមីក្រូហិរញ្ញវត្ថុជាតួអង្គពាក់ព័ន្ធ។"*



ចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុទៅដល់សហគមន៍កសិកម្ម វិស័យធនាគារ គឺជាវិស័យមួយដែលពិតជាមិនអាចខ្វះបាននោះទេ។ លោក ចាន់ សីហា តំណាងធនាគារអភិវឌ្ឍជនបទ និងកសិកម្ម បានរំលេចអំពីការស្វាគមន៍របស់ធនាគារចំពោះសហគមន៍កសិកម្មទាំងអស់ ក្នុងការស្វែងរកឥណទានពីធនាគារ ដែលតួយ៉ាង កន្លងមក ធនាគារ បានចូលរួមជាមួយរាជរដ្ឋាភិបាល ផ្តល់ឥណទាន សម្រាប់វិស័យកសិកម្ម ក្នុងនោះ ក៏ផ្តោតសំខាន់លើវិស័យស្រូវអង្ករផងដែរ ហើយការផ្តល់ឥណទាននេះ បងប្អូនប្រជាកសិករអាចស្វែងរកបានតាមរយៈបណ្តាញការិយាល័យចល័តរបស់ធនាគារ តាមបណ្តាខេត្តមួយចំនួន ដែលមានទីតាំងនៅក្នុងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សហព័ន្ធស្រូវអង្ករកម្ពុជា នឹងនៅតែបន្តខិតខំប្រឹងប្រែងសហការជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជំរុញការចុះកិច្ចសន្យាកសិកម្មរវាងក្រុមហ៊ុន ជាមួយនឹងសហគមន៍កសិកម្ម ឱ្យបានកាន់តែច្រើន ដើម្បីចូលរួមជាមួយនឹងរាជរដ្ឋាភិបាលសម្រេចឱ្យបាននូវគោលដៅការនាំចេញអង្ករ១លានតោន នាពេលខាងមុខ។

គួរបញ្ជាក់ថា សហព័ន្ធស្រូវអង្ករកម្ពុជាបានចូលរួមការងារសហការយ៉ាងសកម្ម ជាមួយគ្រប់នាយកដ្ឋានបច្ចេកទេសទាំងអស់ របស់ក្រសួងកសិកម្ម មានជាអាទិ៍ ដូចជានាយកដ្ឋានកសិ-ឧស្សាហកម្ម ក្នុងការងារកិច្ចសន្យាកសិកម្ម អគ្គនាយកដ្ឋានកសិកម្ម ( GDA ) និងវិទ្យាស្ថានស្រាវជ្រាវកសិកម្មកម្ពុជា ( CARDI ) ក្នុងការសិក្សាស្រាវជ្រាវ និងបញ្ចេញពូជ ស្រូវដែលឆ្លើយតបតាមស្ថានភាព និងទិដ្ឋភាពជាក់ស្តែងនៃទីផ្សារ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ដែលជាលទ្ធផល គឺយើងទើបបានទទួលការបញ្ចេញពូជថ្មីគឺ SKO 01 ដែលសហព័ន្ធ រួមជាមួយ អគ្គនាយកដ្ឋានកសិកម្ម វិទ្យាស្ថានស្រាវជ្រាវកសិកម្មកម្ពុជា និងកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្ម កម្ពុជា- អូស្ត្រាលី CAVAC នឹងត្រៀមរៀបចំសម្ពោធជាផ្លូវការនៅពេលខាងមុខ។

## តម្លៃស្រូវ និងតម្លៃអង្ករនាំចេញ
## (Paddy price & FOB Price)

**សហព័ន្ធស្រូវអង្ករកម្ពុជា** ( Cambodia Rice Federation )

**ប្រធានក្រុមប្រឹក្សាភិបាល ( Chairman )**
*លោកឧកញ៉ា ហ៊ុន ឡាក់ ( Okhna Hun Lak )*

**ប្រធានសហព័ន្ធ ( President )**
*លោកឧកញ៉ា សុង សារ៉ន ( Okhna Song Saran )*

**អគ្គលេខាធិការ ( Secretary General )**
*លោក លន់ យ៉េង ( Mr. Lun Yeng )*

**រៀបរៀង និងចងក្រងដោយ ( Compiled by )**
*កញ្ញា សន ឆវីតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង*
*( Ms. Sorn Chhorvyvatey - Communication Coordinator )*

**រចនាដោយ ( Designed by )**
*កញ្ញា សន ឆវីតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង*
*( Ms. Sorn Chhorvyvatey - Communication Coordinator )*

សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation

តម្លៃអង្ករនាំចេញ FOB Price
as of 05 October 2020

| Rice Varieties | Rice Standard (Price USD/ MT) 5% | 10% | 15% |
|---|---|---|---|
| Jasmine Rice (Malys Angkor) | 880 | | |
| Standard Fragrant Rice_SKO | 720 | | |
| White Rice_Premium (Soft cooking) | 530 | | |
| Parboiled Rice | 550 | | |
| Organic Parboiled Rice (Premium Quality) | 990 | | |
| Organic White Rice (Premium Quality) | | | 900 |
| Organic Jasmine (Malys Angkor) | 1400 | | |
| Organic Brown Jasmine (Premium Quality) | | 1370 | |

**Source :** Cambodian Exporters and Millers
**Note:** Price Fluctuation : +/- 2%

សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation

តម្លៃស្រូវសើម នៅតាមទីតាំង
ដែលកំពុងប្រមូលផល តាមបណ្តាខេត្តមួយចំនួន
ថ្ងៃចន្ទ ទី០៥ ខែតុលា ឆ្នាំ២០២០

| ខេត្ត | ស្រុក | ស្រូវសែនក្រអូប | ស្រូវអ៊ីអែរ/អូអឹម | ស្រូវផ្សេងៗ |
|---|---|---|---|---|
| កំពង់ធំ | តាំងគោក | ១១០០-១១៥០ | ៩០០-៩១០ | |
| | បារាយណ៍ | | ៨២០-៨៣០ | |
| | កំពង់ស្វាយ | | ៨៣០-៨៥០ | |
| | សន្ទុក | | ៨៣០-៨៥០ | |
| សៀមរាប | ជីក្រែង | | ៨២០-៨៣០ | ៨២០-៨៣០ |
| ព្រះវិហារ | ឆែប | ១០៣០-១០៤០ | ៨២០-៨៣០ | |
| បន្ទាយមានជ័យ | ព្រះនេត្រព្រះ | ៩៤០-៩៦០ | | |
| | មង្គលបុរី | ៩៤០-៩៦០ | | |
| | មង្គលបុរី | ៩២០-១០២០ | | |
| បាត់ដំបង | សង្កែ | ១០៥០-១០៨០ | | |
| | បាណន់ | ១០៣០-១០៥០ | | |
| | មោងឫស្សី | ១០២០-១០៤០ | | |
| ពោធិសាត់ | កណ្តៀង | ៩០០-១០៥០ | ៧៧០-៨០០ | |
| កំពង់ឆ្នាំង | កំពង់លែង | | ៨០០-៨៥០ | |

កំណត់សម្គាល់៖
១. សហគមន៍ភ្លោះអភិវឌ្ឍន៍រុងរឿង ស្រុកតាំងគោក ខេត្តកំពង់ធំ (097 488 3065)
២. ប្រធានការិយាល័យកសិកម្ម ស្រុកបារាយណ៍ ខេត្តកំពង់ធំ (012 984 952)
៣. សហគមន៍តារាមចម្រើនផល ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ (092 978 627)
៤. សហគមន៍សន្ទុកក្រៅថ្លុំរីកចម្រើន ស្រុកសន្ទុក ខេត្តកំពង់ធំ (092 329 547)
៥. ប្រធានការិយាល័យកសិកម្មជីក្រែង សៀមរាប (012 637 047)
៦. ក្រុមផលិតស្រូវ (កំពង់រលំ) ស្រុកឆែប ខេត្តព្រះវិហារ (078 576 321)
៧. ប្រធានការិយាល័យកសិកម្ម ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ (092 861 586)
៨. ប្រធានការិយាល័យកសិកម្ម ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ (078 261 114)
៩. សហគមន៍គោកទម្លាប់ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ (012 658 181)
១០. សហគមន៍កំពង់ព្រៀល ស្រុកសង្កែ ខេត្តបាត់ដំបង (078 713 445)
១១. សហគមន៍ទន្លីថ្មីសង្ឃឹមកសិករ ស្រុកបាណន់ ខេត្តបាត់ដំបង (092 532 494)
១២. សហគមន៍ប្រឡាយសាមគ្គី ស្រុកមោងឫស្សី ខេត្តបាត់ដំបង (012 416 242)
១៣. សហគមន៍ព្រែកខ្ពប ស្រុកមោងឫស្សី ខេត្តបាត់ដំបង (015 867 465)
១៤. សហគមន៍ស្បាលចម្រើនផល ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ (017 495 060)
១៥. សហគមន៍ជ្រលងសេកមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង (077 540 310)

អ្នកស្រង់ទិន្នន័យ៖ លោក ទិតសុទ្ធី នីយ៉ាណូរ៉ែន មន្ត្រីសម្របសម្រួលការងារប្រចាំតំបន់៤និង៥ នៃលេខាធិការដ្ឋានស.អ.ក


(855) 23 559 8999
info@crf.org.kh
Soma Tower, 7th Floor
#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh,
Phnom Penh, Cambodia

https://www.facebook.com/cambodiaricefederation/
www.crf.org.kh
https://twitter.com/RiceCrf
សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation